ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ វិទ្យាស្ថានខេមអេដ

*****

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពី ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក. ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១ .-**

ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថានខេមអេដ CAMED INSTITUTE សរសេរកាត់ជាភាសាខ្មែរ វ.ខ.អ និងសរសេរកាត់ជាភាសាអង់គ្លេស C.E.I ។

**មាត្រា ២.-**

វ.ខ.អ មានទីតាំងស្ថិតនៅផ្ទះលេខ៦៤ ផ្លូវលេខ១០៨ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៣ .-**

វ.ខ.អ ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ លើមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដែល ចែកចេញជាបី ដេប៉ាតឺម៉ង់ គឺ ដេប៉ាតឺម៉ង់គណនេយ្យ ដេប៉ាតឺម៉ង់ហិរញ្ញវត្ថុ និង ដេប៉ាតឺម៉ង់គ្រប់គ្រង។ វ.ខ.អ ត្រូវរៀបចំ កម្មវិធីសិក្សាលម្អិតតាមមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួង អប់រំ យុវជន និងកីឡា មុននឹងចាប់ដំណើរ ការបណ្តុះបណ្តាល។

ទៅអនាគតវិទ្យាស្ថាននេះអាចបើកសាខាមហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិត ឬថ្នាក់ថ្មី ប្រភេទ បណ្តុះបណ្តាលថ្មី ប្តូរឈ្មោះថ្មី ឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៤.-**

វ.ខ.អ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការ អភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ ក្រុមប្រឹក្សាភិបាល ត្រូវមានការទទួលស្គាល់ ដោយក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥.-**

នាយក វ.ខ.អ មានភារកិច្ចៈ

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវ.ខ.អ និងធានាឲ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់ សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឲ្យចូលរៀន និងទទួលនិស្សិតឲ្យសិក្សាបន្ត តាមកម្មវិធីសិក្សា របស់វ.ខ.អ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានា គុណភាពអប់រំ

- រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថាន និងវិធានផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងការសិក្សាឲ្យបានច្បាស់លាស់ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួង អប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ មកនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**មាត្រា ៦.-**

និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវផ្តល់ឲ្យដោយ វ.ខ.អ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វ.ខ.អ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាភិបាល រួមទាំងនាយក វ.ខ.អ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ